ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ធំ

សាលក្រមព្រហ្មទណ្ឌលេខ: ៥០ "គ"
ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៣
សំណុំរឿងព្រហ្មទណ្ឌលេខ: ៦០៨
ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣
សំណុំរឿងជំនុំជម្រះលេខ: ៤៣១
ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ធំ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកំពង់ធំ នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង០៨ និង៣០នាទីព្រឹក ដោយមានសមាសភាពជំនុំជម្រះដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ធំ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក អនុប្រធានសាលាដំបូងខេត្តកំពង់ធំ ជាចៅក្រមប្រឹក្សា
លោក ចៅក្រមសាលាដំបូងខេត្តកំពង់ធំ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ធំ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦០៨ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] ឈឹម ភេទប្រុស កើតឆ្នាំ២០០១ អាយុ២២ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី៦ មុខរបរមិនពិតប្រាកដ កើតនៅភូមិប[redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នមុនពេលឃាត់ខ្លួនស្នាក់នៅភូមិ [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ រ៉ែម "រ" ម្តាយឈ្មោះ ឃឹម "រ" ប្រពន្ធឈ្មោះ [redacted] ផល្លី "លែងលះ" កូនគ្មាន។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ)

ដែលជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (កាន់កាំបិតផ្គាក់) ប្រព្រឹត្តនៅចំណុចផ្លូវកោងលើទំនប់អូរចក ខាងកើតស្ពានតាប៉ូ ក្នុងភូមិតាភោគ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី០២ និងថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឈឹម។

ជនរងគ្រោះឈ្មោះ [redacted] សាវី ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិសំពៅលូន ឃុំចើងដើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ជានីតិជន។

-បានឃើញរបាយការណ៍លេខ ០៨១/២០២៣ រ.ប.ក ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៣៧៧/២០២៣ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ: ៤៣១/២០២៣ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ។

-បានឃើញដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៣៧៧១/២០២៣ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។

-បានឃើញភស្តុតាង និងឯកសារពាក់ព័ន្ធក្នុងសំណុំរឿង។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១១ និង០០នាទីព្រឹក ជនជាប់ចោទឈ្មោះ [redacted] ឈឹម ដែលពិការជើងខាងឆ្វេង (កំពុងអបដែក) បានលីកាំបិតផ្គាក់០១ដើម ដើរសំដៅទៅចំការរបស់ខ្លួន ប៉ុន្តែពេលដើរដល់ចំណុចផ្លូវកោងលើទំនប់អូរចក ខាងកើតស្ពានតាប៊ី ស្ថិតនៅភូមិតាអោគ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដោយឃើញសភាពស្ងាត់ ជនជាប់ចោទឈ្មោះ [redacted] ឈឹម ក៏ពួនស្ទាក់នៅក្នុងគុម្ពោតព្រៃក្បែរផ្លូវ ដើម្បីស្ទាក់ចាំគម្រាមប្លន់យកទ្រព្យសម្បត្តិប្រជាពលរដ្ឋ។ លុះដល់វេលាម៉ោងប្រហែល១៣ និង១០នាទីថ្ងៃត្រង់ ពេលឃើញជនរងគ្រោះឈ្មោះ [redacted] សាវី ភេទស្រី ជិះម៉ូតូជាមួយក្មេងស្រីចំនួន០២នាក់មកដល់ ជនជាប់ចោទឈ្មោះ [redacted] ឈឹម ក៏ស្ទុះចេញពីគុម្ពោតព្រៃមកស្ទាក់ម៉ូតូរបស់ជនរងគ្រោះ រួចគម្រាមយកកាបូបស្ពាយរបស់ជនរងគ្រោះ ដែលនៅក្នុងនោះមាន ទូរស័ព្ទដៃម៉ាក OPPO ចំនួន០១គ្រឿង និងប្រាក់ចំនួន ៧៧០.០០០(ចិតសិបប្រាំពីរម៉ឺន)រៀល។ បន្ទាប់ពីធ្វើសកម្មភាពរួច ជនជាប់ចោទឈ្មោះ [redacted] ឈឹម ក៏ដើរតាមផ្លូវដើម្បីគេចខ្លួន ប៉ុន្តែនៅតាមផ្លូវ ដោយជួបជាមួយឈ្មោះ [redacted] ស៊ាន់ កំពុងបើកបរគោយន្ត ជនជាប់ចោទឈ្មោះ [redacted] ឈឹម ក៏សុំជិះទៅជាមួយ។ ពេលជិះមកដល់ផ្ទះរបស់ឈ្មោះ [redacted] ស៊ាន់ ដោយឃើញម៉ូតូរបស់ឈ្មោះ [redacted] ស៊ាន់ ចតទុកចោល ជនជាប់ចោទឈ្មោះ [redacted] ឈឹម ក៏សុំខ្ចីម៉ូតូនោះជិះគេចខ្លួន រួចយកទៅទុកនៅផ្ទះរបស់ឈ្មោះ [redacted] សុផល ហើយគេចខ្លួនតែម្តង។ លុះដល់ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០២៣ ពេលឈ្មោះ [redacted] ឈឹម កំពុងដេកនៅក្រោយផ្ទះ ក៏ត្រូវសមត្ថកិច្ចចុះទៅធ្វើការឃាត់ខ្លួន ដោយដកហូតបានកាំបិតផ្គាក់ ចំនួន០១ដើម និងទូរស័ព្ទដៃម៉ាក OPPO ចំនួន០១គ្រឿង យកមកសាកសួរ រួចកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងខេត្តកំពង់ធំ ចាត់ការបន្តតាមនីតិវិធីច្បាប់។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ឈឹម បានឆ្លើយថា៖ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១១ និង០០នាទីព្រឹក ខ្លួនបានលីកាំបិតផ្គាក់០១ដើម ដើរសំដៅទៅវាល(ចំការ)របស់ខ្លួន ប៉ុន្តែពេលដើរដល់ចំណុចផ្លូវកោងលើទំនប់អូរចក ខាងកើតស្ពានតាប៊ី ស្ថិតនៅភូមិតាអោគ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដោយឃើញសភាពស្ងាត់ ខ្លួនក៏ពួនក្នុងគុម្ពោតព្រៃក្បែរផ្លូវ ដើម្បីស្ទាក់ចាំគម្រាមប្លន់យកទ្រព្យសម្បត្តិប្រជាពលរដ្ឋ។ លុះដល់វេលាម៉ោងប្រហែល១៣ និង១០នាទីថ្ងៃត្រង់ ពេលឃើញមនុស្សស្រីម្នាក់ជិះម៉ូតូឌុបក្មេងស្រីចំនួន០២នាក់មកដល់ ខ្លួនក៏ស្ទុះចេញពីគុម្ពោតព្រៃទៅស្ទាក់ម៉ូតូរបស់គាត់ គម្រាមយកបានកាបូបស្ពាយចំនួន០១ ដែលនៅក្នុងនោះមានទូរស័ព្ទដៃម៉ាក OPPO ចំនួន០១គ្រឿង និងប្រាក់ប្រហែល០១លានរៀល ដោយពុំបានវាយ ឬដណ្តើមយកម៉ូតូរបស់គាត់ទេ។ បន្ទាប់ពីធ្វើសកម្មភាពរួច ខ្លួនក៏ដើរតាមផ្លូវដើម្បីគេចខ្លួន ប៉ុន្តែដោយបានជួបជាមួយឈ្មោះ [redacted] ស៊ាន់ កំពុងបើកបរគោយន្ត ខ្លួនក៏សុំជិះទៅជាមួយ។ ពេលជិះទៅដល់ផ្ទះរបស់ឈ្មោះ [redacted] ស៊ាន់ ខ្លួនក៏សុំខ្ចីម៉ូតូរបស់គាត់ជិះគេចខ្លួន ដោយយកម៉ូតូនោះទៅទុកនៅផ្ទះរបស់ឈ្មោះ [redacted] សុផល ហើយគេចខ្លួនតែម្តង។ លុះដល់ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ ពេលខ្លួនកំពុងដេកនៅក្រោយផ្ទះ ក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួន ដោយដកហូតបានកាំបិតផ្គាក់ ចំនួន០១ដើម និងទូរស័ព្ទដៃម៉ាក OPPO ចំនួន០១គ្រឿង យកទៅធ្វើការសាកសួរ។ ទូរស័ព្ទដែលខ្លួនលួចបាននោះ ត្រូវសមត្ថ

កិច្ចប្រគល់ម្ចាស់វិញហើយ។ ឯប្រាក់ប្រហែល១.០០០.០០០រៀលនោះ ខ្លួនបានចាយវាយអស់មុនពេលសមត្ថកិច្ចឃាត់ខ្លួន។ ខ្លួនសូមបញ្ជាក់ថា ខ្លួនបានធ្វើសកម្មភាពគម្រោងយកការបូបពីមនុស្សស្រីនោះតែនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ ប៉ុណ្ណោះ។

-អំណានចម្លើយដើមបណ្តឹងឈ្មោះ [redacted] សារី នៅចំពោះមុខចៅក្រមស៊ើបសួរថា៖ ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ទុកនៅដដែល។ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ ខ្លួនបានជិះម៉ូតូទៅលេងផ្ទះម្តាយក្មេកនៅភូមិតាភោគ ឃុំបល្ល័ង្គ ដោយមានឪពុកក្មេកម្នាក់ និងកូនម្នាក់ ព្រមទាំងមានកាបូបស្ពាយពណ៌ផ្កាឈូក ចំនួន០១ ដែលនៅក្នុងនោះមានលុយចំនួន៧៧០.០០០(ចិតសិបប្រាំពីរម៉ឺន)រៀល ទូរស័ព្ទដៃ០១គ្រឿង និងអត្តសញ្ញាណប័ណ្ណ០១សន្លឹក ដោយជិះតាមផ្លូវខ្វាងទំនប់អូរចក។ លុះពេលត្រឡប់មកវិញ ដល់ចំណុចផ្លូវកោង ខាងកើតភូមិតាភោគ ស្រាប់តែមានមនុស្សប្រុសម្នាក់ ពាក់អាវខ្មៅ ស្លៀកខោខ្លី ជើងស្តាំមានដាក់ដែក (បាក់ជើង) បានកាន់កាំបិតផ្គាក់មកស្ទាក់ផ្លូវ គម្រោងយកកាបូបស្ពាយរបស់ខ្លួន។ ពេលនោះដោយភ័យពេកខ្លួនក៏ផ្តួលម៉ូតូ ហើយមនុស្សប្រុសម្នាក់នោះក៏ឆក់យកកាបូបពីដៃខ្លួន រួចដើរទៅទិសខាងលិចបាត់។ បន្ទាប់មកខ្លួនក៏ជិះម៉ូតូត្រឡប់ទៅផ្ទះម្តាយក្មេកខ្លួនវិញ ប៉ុន្តែនៅតាមផ្លូវ ក៏បានជួបជាមួយឈ្មោះ ណាង ហើយខ្លួនក៏និយាយរឿងនេះប្រាប់គាត់ៗ ក៏នាំខ្លួនទៅប្តឹងនៅប្រជាការពារភូមិតែម្តង។ ពេលនេះជនដែលស្ទាក់ប្លន់កាបូបរបស់ខ្លួននោះត្រូវបានប៉ូលីសចាប់បានហើយ វាមានឈ្មោះ [redacted] ឈឹម រស់នៅភូមិបល្ល័ង្គ។ ខ្លួនក៏បានទទួលទូរស័ព្ទមកវិញហើយដែរ ប៉ុន្តែលុយត្រូវវាចាយបាត់អស់ហើយ។ ពេលនេះខ្លួនសុំដកពាក្យបណ្តឹងឈប់ប្តឹងផ្តល់ ឬទាមទារសំណងអ្វីទៀតហើយ និងសំណូមពរតុលាការមេត្តាឈប់កោះហៅខ្លួនមកទៀត ពីព្រោះខ្លួនមានកូនតូចពិបាកក្នុងការធ្វើដំណើរម្យ៉ាងគ្មានអ្នកមើលកូននៅផ្ទះ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ស៊ាន់ នៅចំពោះមុខចៅក្រមស៊ើបសួរថា៖ ខ្លួនសូមរក្សាចម្លើយដូចដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ទុកនៅដដែល ដោយកាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ ម៉ោងប្រហែល០២រសៀលពេលខ្លួនបើកបរគោយន្តមកពីស្រែក៏បានជួបជាមួយឈ្មោះ [redacted] ឈឹម ហើយវាបានសុំជិះគោយន្តជាមួយ។ ពេលជិះមកដល់ផ្ទះខ្លួន វាបានសួរថាម៉ូតូជិះកើតឬទេ? ក្រោយពេលខ្លួនឆ្លើយថា “ជិះកើត” វាក៏យកម៉ូតូរបស់ខ្លួនជិះចេញទៅបាត់។ លុះដល់ពេលល្ងាចមិនឃើញយកម៉ូតូមកឱ្យខ្លួនវិញ ទើបខ្លួនទៅរាយការណ៍ជូនសមត្ថកិច្ច។ ក្រោយមកពូរបស់ខ្លួនបានប្រាប់ថាឃើញឈ្មោះ ឈឹម ជិះម៉ូតូចូលផ្ទះរបស់ឈ្មោះ ផល ទើបខ្លួនទៅមើល ឃើញម៉ូតូរបស់ខ្លួនទុកចោលទៅទីនោះមែន ប៉ុន្តែមិនឃើញឈ្មោះ ឈឹម ទេហើយខ្លួនក៏យកម៉ូតូមកផ្ទះវិញ។ [redacted]

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ឌុក នៅចំពោះមុខចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ ម៉ោងប្រហែល០៩.០០ព្រឹក ខ្លួនបានដេញក្របីទៅឃ្វាលនៅខាងកើតភូមិតាភោគ។ លុះដល់ម៉ោងប្រហែល១១.០០ថ្ងៃត្រង់ ពេលខ្លួនដើរលើខ្នងទំនប់ ក៏បានឃើញមនុស្សប្រុសម្នាក់ ពាក់អាវខ្មៅដៃវែង ស្លៀកខោខ្លីត្រឹមជង្គង់ យកអាវខ្មៅរុំមុខ និងជើងខាងស្តាំយកក្រម៉ារុំ មានកាំបិតផ្គាក់១ដើម។ ពេលឃើញខ្លួនវាក៏រត់ពួន តែខ្លួនមិនចាប់អារម្មណ៍។ បន្ទាប់មកពេលប្រពន្ធ និងកូនរបស់ខ្លួនមកដល់ខ្លួនក៏ជិះម៉ូតូជាមួយប្រពន្ធទៅផ្ទះ ចំណែកកូននៅឃ្វាលក្របីបន្ត។ លុះដល់ម៉ោងប្រហែល១៣.០០រសៀលស្រាប់តែផ្អើលឆោឡោថាមានចោរប្លន់អ្នកភូមិនៅស្ពានតាប៊ូ ខ្លួនក៏ចេញទៅជាមួយគេ នាំគ្នាជិះទូក០២គ្រឿងមានគ្នា៥នាក់ តាមរកឃើញទូករបស់ខ្លួននៅម្តុំទួលក្រសាំង ប៉ុន្តែមិនឃើញជនសង្ស័យ។ បន្ទាប់មកក៏ឮតៗគ្នាថា ឃើញជនសង្ស័យដើរនៅតំបន់បាក់ផែង ទើបពួកខ្លួនជិះម៉ូតូតាមរកទៀត ប៉ុន្តែនៅតែរកមិនឃើញដដែល។ លុះដល់ល្ងាច ក៏ឮមន្ត្រីនគរបាលប្រាប់ថា វាបានចូលទៅយកម៉ូតូរបស់អ្នកភូមិបាក់ផែង ០១គ្រឿងទៀត ជិះគេចខ្លួនបាត់ហើយ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] យឿង នៅចំពោះមុខចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ ម៉ោងប្រហែល១២.០០ថ្ងៃត្រង់ កូនប្រសារខ្លួនឈ្មោះ [redacted] សារី បានជិះម៉ូតូមកលេងខ្លួននៅភូមិតាភោគ។ លុះដល់ម៉ោងប្រ-

ហែល១៣.០០រសៀល ទើបកូនប្រសាររបស់ខ្លួនត្រឡប់ទៅវិញ។ លុះម៉ោងប្រហែល១៣ និង៣០នាទី ស្រាប់តែឃើញកូនប្រសារត្រឡប់មកវិញ ដោយប្រាប់ថា វាត្រូវចោរប្លន់យកលុយអស់ជាង៧០០,០០០(ចិតសិបម៉ឺន)រៀល និងទូរស័ព្ទដៃមួយគ្រឿងទៀត។ ពេលនេះជនដែលប្លន់កូនប្រសារខ្លួនត្រូវប៉ូលីសចាប់បានហើយ វាមានឈ្មោះ [redacted] ឈឹម រស់នៅភូមិបល្ល័ង្ក។ កូនប្រសាររបស់ខ្លួនបានទទួលទូរស័ព្ទរបស់វាវិញហើយ ប៉ុន្តែលុយត្រូវចោរចាយអស់បាត់ហើយ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] សុខនៃ នៅចំពោះមុខចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង១៩.០០ល្ងាច មានមនុស្សប្រុសម្នាក់ពាក់អាវយឺតខ្មៅ ស្លៀកខោខ្លី ហើយនៅជើងខាងស្តាំមានដាក់ឆ្អឹងដែកដូចអង់តែនទូរទស្សន៍ ជិះម៉ូតូអាសង់ពណ៌ខ្មៅ ចូលមករកច្រៀងខារ៉ាអូខេ។ ពេលនោះថៅកែក៏បើកឱ្យចូលច្រៀង ដោយមាននារី២នាក់ចូលច្រៀងជាមួយ។ លុះដល់ម៉ោងប្រហែល២០ និង០០នាទីយប់ គិតលុយអស់ចំនួន១០០.០០០(ដប់ម៉ឺន)រៀល ប៉ុន្តែបុរសម្នាក់នេះថាអត់មានលុយឱ្យទេ ហើយគាត់សុំបញ្ចាំទូរស័ព្ទដៃម៉ាកអូប៉ូ ចំនួន០១គ្រឿង។ ខ្លួនក៏យកទូរស័ព្ទនេះទៅសួរមេ ដោយឃើញទូរស័ព្ទនោះនៅថ្មី គាត់ក៏ព្រមទទួលបញ្ចាំ ហើយបុរសម្នាក់នោះក៏ជិះម៉ូតូចេញទៅបាត់។ ពួកខ្លួនមិនបានដឹងថាបុរសម្នាក់ដែលដាក់បញ្ចាំទូរស័ព្ទនេះ គឺជាចោរនោះទេ។ ពេលនេះពួកខ្លួនបានប្រគល់ទូរស័ព្ទ០១គ្រឿងនោះឱ្យម្ចាស់គេវិញហើយ។ ខ្លួនបានដឹងរឿងរ៉ាវតែត្រឹមនេះទេ អ្វីក្រៅពីនេះខ្លួនមិនបានដឹងឡើយ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ស៊ី នៅចំពោះមុខចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ ម៉ោង១៤.០០រសៀល ពេលខ្លួននៅផ្ទះ ក៏ឃើញកូនប្រុសខ្លួនឈ្មោះ ស៊ាន់ បើកបរគោយន្តមកពីស្រែ ដោយមានឈ្មោះ [redacted] ឈឹម ជិះមកជាមួយ។ ពេលមកដល់ភ្លាមឈ្មោះ [redacted] ឈឹម ស្រែកសួរកូនខ្លួនថា "ម៉ូតូជិះកើតអត់?"។ ពេលនោះដោយឮកូនរបស់ខ្លួនឆ្លើយថា "ជិះកើត" ឈ្មោះ [redacted] ឈឹម ក៏ឡើងជិះម៉ូតូនោះចេញទៅបាត់។ បន្តិចក្រោយមកក៏មានប្រជាការពារភូមិបល្ល័ង្ក មកសួរថាមានឃើញឈ្មោះ [redacted] ឈឹម មកទីនេះឬទេ?។ បន្ទាប់ពីខ្លួនឆ្លើយថា "ឃើញវាយកម៉ូតូកូនខ្លួនជិះទៅបាត់ហើយ" ប្រជាការពារភូមិនោះក៏ប្រាប់ខ្លួនថា ឈ្មោះ ឈឹម បានប្លន់គេមកពីភូមិតាអោគ។ ពេលលឺដូចនេះខ្លួនក៏ប្រាប់ឱ្យកូនទៅប្តឹងរាយការណ៍ជូនសមត្ថកិច្ចតែម្តង។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ផល នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១០ និង០០នាទីព្រឹក មិត្តភក្តិរបស់ខ្លួនឈ្មោះ កុសល់ បានទិញស្រាថ្នាំចំនួន២លីត្រ មកផឹកស៊ីនៅផ្ទះរបស់ខ្លួន រហូតដល់ព្រលប់ស្រាក៏អស់ រូបខ្លួនក៏ស្រវឹង មិត្តរបស់ខ្លួនក៏សុំទៅផ្ទះមុន ហើយខ្លួនក៏ចូលទៅដេកលក់នៅក្នុងអង្រឹងក្រោមផ្ទះ។ រហូតដល់វេលាម៉ោងប្រហែល០៨.០០យប់ ក៏មានឈ្មោះ ស៊ាន់ មកដាស់ខ្លួន ហើយសួរថា មានឃើញឈ្មោះ [redacted] ឈឹម យកម៉ូតូមកទុកនៅផ្ទះខ្លួនឬទេ? ពីព្រោះឈ្មោះ ប៊ិន បានទូរស័ព្ទប្រាប់ថា អាឈឹម ជិះម៉ូតូចូលមកផ្ទះខ្លួន។ ពេលនោះខ្លួនក៏បានងើបអង្គុយមើលក៏ឃើញម៉ូតូនោះ នៅខាងកើតផ្ទះ ទើបប្រាប់ឱ្យឈ្មោះ ស៊ាន់ យកម៉ូតូទៅវិញចុះ។ បន្ទាប់មកឈ្មោះ ស៊ាន់ ក៏អូសម៉ូតូជិះចេញទៅវិញ ឯរូបខ្លួនក៏ចូលដេកវិញទៅ។

-អំណានរបាយការណ៍សរុបលេខ ០៨១/២០២៣ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ, អំណានចម្លើយជនរងគ្រោះ, អំណានចម្លើយសាក្សី និងអំណានភស្តុតាងជាឯកសារផ្សេងៗ ក្នុងសំណុំរឿងរួចមកឃើញថា ជនជាប់ចោទឈ្មោះ [redacted] ឈឹម

បានសារភាព កាលពីថ្ងៃទី០២ និងថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១៣ និង១០នាទីថ្ងៃត្រង់ រូបគេពិតជាកាន់កាំបិតផ្គាក់០១ដើម ពួនស្ទាក់ចាំគម្រាមប្លន់យកទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋនៅចំណុចផ្លូវកោងលើទំនប់អូរចក ខាងកើតស្ពានតាប៊ូ ស្ថិតនៅភូមិតាសោគ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ និងបានគម្រាមយកបានកាបូបស្ពាយរបស់ជនរងគ្រោះឈ្មោះ [redacted] សាវី ដែលនៅក្នុងនោះមានទូរស័ព្ទដៃម៉ាក OPPO ចំនួន០១គ្រឿង និងប្រាក់ចំនួនជាង៧០០.០០០(ចិតសិបម៉ឺន)រៀលប្រាកដមែន។ ការប្រើកាំបិតផ្គាក់ស្ទាក់គម្រាមយកទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ដែលប្រព្រឹត្តដោយជនជាប់ចោទរូបនេះត្រូវបានច្បាប់កំណត់ជាអំពើលួចមានស្ថានទម្ងន់ទោស ដែលមានបញ្ញត្តិតាមមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។ ដូច្នេះតំណាងអយ្យការនៅតែរក្សាការប្ដឹងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទ ដូចក្នុងដីកាសន្និដ្ឋានស្ថាពរទាំងស្រុងដដែល។

**សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានការពារថា ក្រោយពីបានស្ដាប់ការសាកសួរដេញដោល និងស្ដាប់អំណានចម្លើយជនដែលពាក់ព័ន្ធនាពេលសវនាការរួចមកឃើញថា៖ កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] ឈឹម បានសារភាពថា ថ្ងៃកើតហេតុរូបគេពិតជាបានប្រើកាំបិតផ្គាក់ ពួនស្ទាក់ចាំគម្រាមយកទ្រព្យសម្បត្តិពីប្រជាពលរដ្ឋ ហើយថ្ងៃនោះគាត់ពិតជាបានគម្រាមយកកាបូបស្ពាយដែលមានទូរស័ព្ទដៃ ចំនួន០១គ្រឿង និងប្រាក់មួយចំនួន ពីជនរងគ្រោះឈ្មោះ [redacted] សាវី បានសម្រេចប្រាកដមែន ប៉ុន្តែក្រោយពេលឃាត់ខ្លួន គាត់បាននាំសមត្ថកិច្ចទៅយកទូរស័ព្ទរបស់ជនរងគ្រោះ ប្រគល់ជូនជនរងគ្រោះវិញហើយ។ ដូច្នេះក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្ញុំសូមឱ្យក្រុមប្រឹក្សាជំនុំជម្រះ ពិចារណា និងផ្ដន្ទាទោសគាត់ក្នុងកម្រិតអប្បបរមាដោយអនុគ្រោះផង ពីព្រោះគាត់ពុំធ្លាប់ត្រូវបានតុលាការផ្ដន្ទាទោសពីមុនមកទេ ហើយអំពើរបស់គាត់ក៏ពុំបណ្ដាលឱ្យមានរបួសដល់ជនរងគ្រោះដែរ។ គាត់ធ្វើសកម្មភាពនេះឡើង គ្រាន់តែដើម្បីបានប្រាក់បន្តិចបន្តួចមកចាយវាយប៉ុណ្ណោះ ពីព្រោះគាត់ជាជនមានពិការភាព ក្រីក្រ ពុំមានមុខរបរសម្រាប់ចិញ្ចឹមជីវិត និងមានវិបត្តិផ្លូវចិត្តដោយសារការលែងលះពីប្រពន្ធ។

**សំណូមពររបស់ជនជាប់ចោទ**

ជនជាប់ចោទឈ្មោះ [redacted] ឈឹម សំណូមពរថា៖ ខ្លួនសូមឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួន ដើម្បីឆាប់បានវិលត្រលប់ទៅរស់នៅក្នុងសង្គមជាតិវិញផង ខ្លួនទទួលស្គាល់កំហុសហើយៗ ខ្លួនសូមសន្យាពេលបានចេញពីពន្ធនាគារវិញ ខ្លួនប្រព្រឹត្តអំពើល្មើសនឹងច្បាប់ទៀតហើយ។

-ក្រោយពីបានស្ដាប់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្ដាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន និងប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សំណូមពររបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិនិត្យ ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សំអាងហេតុ</u>**

១-មានសាក្សីគ្រប់គ្រាន់ និងភស្តុតាងស៊ីសង្វាក់បញ្ជាក់ថា: កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង១៣ និង



Scanned with CamScanner

១០នាទីថ្ងៃត្រង់ ពិតជាមានករណីប្រើកាំបិតផ្គាក់ពួនស្ទាក់គម្រោមយកទ្រព្យសម្បត្តិប្រជាពលរដ្ឋបានសម្រេច កើតឡើងនៅចំណុចផ្លូវកោងលើទំនប់អូរចក ខាងកើតស្ពានតាប៊ូ ក្នុងភូមិតាអោគ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ប្រាកដមែន។

២-ជនជាប់ចោទឈ្មោះ [redacted] ឈឹម បានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលនៃការសាកសួរ ក៏ដូចជានាពេលសវនាការថា៖ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១១ និង០០នាទីព្រឹក ខ្លួនបានលីកាំបិតផ្គាក់០១ដើម ដើរសំដៅទៅវាល(ចំការ)របស់ខ្លួន ប៉ុន្តែពេលដើរដល់ចំណុចផ្លូវកោងលើទំនប់អូរចក ខាងកើតស្ពានតាប៊ូ ស្ថិតនៅភូមិតាអោគ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដោយឃើញសភាពស្ងាត់ ខ្លួនក៏ពួនក្នុងគុម្ពោតព្រៃក្បែរផ្លូវ ដើម្បីស្ទាក់ចាំគម្រាមប្លន់យកទ្រព្យសម្បត្តិប្រជាពលរដ្ឋ។ លុះដល់វេលាម៉ោងប្រហែល១៣ និង១០នាទីថ្ងៃត្រង់ ពេលឃើញមនុស្សស្រីម្នាក់ជិះម៉ូតូឌុបក្មេងស្រីចំនួន០២នាក់មកដល់ ខ្លួនក៏ស្ទុះចេញពីគុម្ពោតព្រៃទៅស្ទាក់ម៉ូតូរបស់គាត់ គម្រាមយកបានកាបូបស្ពាយចំនួន០១ ដែលនៅក្នុងនោះមានទូរស័ព្ទដៃម៉ាក OPPO ចំនួន០១គ្រឿង និងប្រាក់ប្រហែល០១លានរៀល ដោយពុំបានវាយ ឬដណ្តើមយកម៉ូតូរបស់គាត់ទេ។ ចម្លើយសារភាពនេះ មានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយឱ្យការណ៍របស់ជនរងគ្រោះឈ្មោះ [redacted] សាវី ដែលបានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ ពេលខ្លួនជិះម៉ូតូត្រលប់មកពីលេងផ្ទះម្តាយក្មេកនៅភូមិតាអោគ ឃុំបល្ល័ង្ក តាមផ្លូវខ្នងទំនប់អូរចក មកដល់ចំណុចផ្លូវកោង ខាងកើតភូមិតាអោគ ក៏ត្រូវមនុស្សប្រុសម្នាក់ពាក់អាវខ្មៅ ស្លៀកខោខ្លី ជើងស្តាំមានដាក់ដែក(បាក់ជើង) បានកាន់កាំបិតផ្គាក់មកស្ទាក់ផ្លូវ គម្រាមយកកាបូបស្ពាយរបស់ខ្លួនដែលនៅក្នុងនោះមានលុយចំនួន៧៧០.០០០ (ចិតសិបប្រាំពីរម៉ឺន)រៀល និងទូរស័ព្ទដៃ ចំនួន០១គ្រឿង និងអត្តសញ្ញាណប័ណ្ណ០១សន្លឹកតែម្តង ហើយក៏ស៊ីសង្វាក់ទៅនឹងភស្តុតាងដែលសមត្ថកិច្ចបានដកហូតពីជនជាប់ចោទ ក្រោយពេលប្រព្រឹត្តអំពើល្មើសមានកាំបិតផ្គាក់ចំនួន០១ដើមផងដែរ។ ចម្លើយសារភាពរបស់ជនជាប់ចោទ មានភាពច្បាស់លាស់អាចឱ្យតុលាការជឿបាន។

៣-តាមដីកាដំណោះស្រាយ(បញ្ជូនសំណុំរឿងទៅជំនុំជម្រះ)លេខ ៣៧៧១/២០២៣ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ចៅក្រមស៊ើបសួរបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted]ឈឹម ភេទប្រុស អាយុ២២ឆ្នាំ ទៅជំនុំជម្រះពីបទលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (កាន់កាំបិតផ្គាក់) ប្រព្រឹត្តនៅចំណុចផ្លូវកោងលើទំនប់អូរចក ខាងកើតស្ពានតាប៊ូ ក្នុងភូមិតាអោគ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី០២ និងថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៣ តាមមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ប៉ុន្តែក្រោយពីបានស្តាប់ការសាកសួរដេញដោលនាពេលសវនាការ ក៏ដូចជាការពិនិត្យភស្តុតាងផ្សេងៗ និងស្តាប់អំណានចម្លើយរបស់ជនដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងរួចមកឃើញថា៖ ទាំងរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ ជនជាប់ចោទ ជនរងគ្រោះ រួមទាំងសាក្សីផងសុទ្ធតែបានបញ្ជាក់ដូចគ្នាៗថា៖ ជនជាប់ចោទបានប្រព្រឹត្តអំពើល្មើសតែនៅថ្ងៃទី០៣ ខែសីហា មួយថ្ងៃប៉ុណ្ណោះ ពុំមានអង្គហេតុប្រព្រឹត្តនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ឡើយ។ គប្បីតុលាការពិចារណា និងសម្រេចផ្តន្ទាទោសជនជាប់ចោទនេះ តែទៅលើអង្គហេតុដែលបានប្រព្រឹត្តនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០២៣ ប៉ុណ្ណោះ។

៤-តាមចម្លើយជនជាប់ចោទ, អំណានចម្លើយជនរងគ្រោះ អំណានចម្លើយសាក្សី និងភស្តុតាងផ្សេងៗ ដែលមាននៅក្នុងសំណុំរឿងឃើញថា កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១៣ និង១០នាទីថ្ងៃត្រង់ ជនជាប់ចោទឈ្មោះ [redacted] ឈឹម ពិតជាមានចេតនា និងបានធ្វើសកម្មភាពប្រើកាំបិតផ្គាក់ពួនស្ទាក់គម្រាមយកទ្រព្យសម្បត្តិ(កាបូបស្ពាយដែលក្នុងមានទូរស័ព្ទដៃម៉ាក OPPO ចំនួន០១គ្រឿង និងប្រាក់ចំនួន៧៧០.០០០រៀល) ពីជនរងគ្រោះឈ្មោះ [redacted] សាវី បានសម្រេចប្រាកដមែន។ ការដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងគោលបំណងយកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយការប្រើអំពើហិង្សា ដែលប្រព្រឹត្តដោយជនជាប់ចោទនេះ ត្រូវបានច្បាប់កំណត់ជាអំពើលួចមានស្ថានទម្ងន់ទោស ដែលមាន



Scanned with CamScanner

បញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

៥-អំពើលួចមានស្ថានទម្ងន់ទោស ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ឈឹម បានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសង្គមជាតិ ជាពិសេសបានធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ និងអាចបណ្តាលឱ្យប៉ះពាល់ដល់បូរណភាពរាងកាយ និងអាយុជីវិតរបស់ជនរងគ្រោះផងដែរ។

៦-នៅពេលប្រព្រឹត្តអំពើល្មើស ជនជាប់ចោទឈ្មោះ [redacted] ឈឹម កើតឆ្នាំ២០០១ មានអាយុ២២ឆ្នាំ ជានីតិជន មិនមានសញ្ញាណណាមួយ ដែលនាំឱ្យមានការសង្ស័យអំពីបញ្ហាស្មារតីរបស់ជននេះក្នុងពេលប្រព្រឹត្តល្មើសឡើយ នេះបញ្ជាក់ឱ្យឃើញថាជនជាប់ចោទ ជាមនុស្សអាចយល់ ដឹងនូវអំពើ និងព្យសនកម្មដែលកើតចេញពីអំពើដែលគេបានប្រព្រឹត្តនោះ។ គប្បីតុលាការពិនិត្យ ពិចារណា និងផ្តន្ទាទោសជនជាប់ចោទនេះតាមច្បាប់។

៧-ជនជាប់ចោទឈ្មោះ [redacted] ឈឹម ធ្លាប់បានទទួលការអប់រំរៀនសូត្រត្រឹមថ្នាក់ទី៦ ពុំមានមុខរបរពិតប្រាកដ ជាមនុស្សមានពិការភាព(បាក់ជើង) កំព្រាឪពុក មានជីវភាពក្រីក្រ និងមានវ័យនៅក្មេងអាចមានឱកាសកែខ្លួនក្លាយទៅជាមនុស្សល្អមានប្រយោជន៍ដល់សង្គមជាតិវិញ។ ជនជាប់ចោទទើបតែប្រព្រឹត្តអំពើល្មើសជាលើកទី១ ពុំធ្លាប់មានប្រវត្តិផ្តន្ទាទោសដោយតុលាការពីមុនមកទេ។ ម្យ៉ាងវិញទៀតព្យសនកម្មដែលកើតចេញពីអំពើលួចមានស្ថានទម្ងន់ទោស របស់ជនជាប់ចោទនេះ ក៏ពុំមានលក្ខណៈធ្ងន់ធ្ងរអ្វីដល់ជនរងគ្រោះដែរ ពោលគឺជនរងគ្រោះបាត់បង់តែប្រាក់ចំនួន៧៧០.០០០រៀលប៉ុណ្ណោះ។ គប្បីតុលាការលើកយកមកពិចារណា ដើម្បីផ្តន្ទាទោសជនជាប់ចោទក្នុងកម្រិតអប្បបរមា។

៨-វត្ថុតាងចាប់យកដែលសមត្ថកិច្ចការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] ឈឹម មាន៖ កាំបិតផ្គាក់ ចំនួន០១ដើម, ទូរស័ព្ទដៃម៉ាកអូប៉ូ (OPPO) ពណ៌ខៀវ ម៉ូដែល CPH2185 ចំនួន០១គ្រឿង និងអាវដៃវែងពណ៌ខ្មៅ ចំនួន០១។ វត្ថុតាងចាប់យក: កាំបិតផ្គាក់ ចំនួន០១ដើម ពិតជាមធ្យោបាយដែលជនជាប់ចោទប្រើក្នុងការប្រព្រឹត្តអំពើល្មើសប្រាកដមែន។ គប្បីរឹបអូសតាមបទប្បញ្ញត្តិមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ ឯវត្ថុតាងចាប់យកផ្សេងៗទៀតពុំមានពាក់ព័ន្ធ ឬជាមធ្យោបាយដែលជនជាប់ចោទប្រើក្នុងការប្រព្រឹត្តអំពើល្មើសឡើយ។ គប្បីប្រគល់សងទៅម្ចាស់ដើមឈ្មោះ [redacted] ឈឹម វិញតាមបទប្បញ្ញត្តិមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

៩-នៅចំពោះមុខចៅក្រមស៊ើបសួរ ជនរងគ្រោះឈ្មោះ [redacted] សាវី បានបញ្ជាក់ថា ក្នុងរឿងនេះ ខ្លួនពុំប្តឹងទាមទារសំណងអ្វីពីជនជាប់ចោទរូបនេះទេ។ តុលាការពុំគប្បីលើកយកបញ្ហាសំណងរដ្ឋប្បវេណីមកពិចារណា និងសម្រេចសេចក្តីឡើយ។

១០-ក្រោយពេលប្រព្រឹត្តអំពើល្មើស ជនជាប់ចោទឈ្មោះ [redacted] ឈឹម ត្រូវបានសមត្ថកិច្ចការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ឃាត់ខ្លួននៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ រួចបញ្ជូនមកសាលាដំបូងខេត្តកំពង់ធំ ហើយត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ បង្គាប់ឱ្យឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ធំ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៧៤/២០២៣ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ រួចហើយ។

១១-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ, អំណានចម្លើយជនរងគ្រោះ, អំណានចម្លើយសាក្សី និងអំណានភស្តុតាងជាឯកសារផ្សេងៗ ក្នុងសំណុំរឿងរួចមកឃើញថា ជនជាប់ចោទឈ្មោះ [redacted] ឈឹម បានសារភាព កាលពីថ្ងៃទី០២ និងថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១៣ និង១០នាទីថ្ងៃត្រង់ រូបគេពិតជាកាន់កាំបិតផ្គាក់០១ដើម ពួនស្ទាក់ចាំគម្រាមប្លន់យកទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋនៅចំណុចផ្លូវកោងលើទំនប់អូរចក ខាងកើតស្ពានតាប៊ូ ស្ថិតនៅភូមិតាភោគ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ និងបានគម្រាមយកបានកាបូបស្ពាយរបស់ជនរងគ្រោះ

ឈ្មោះ [redacted] សាវី ដែលនៅក្នុងនោះមានទូរស័ព្ទដៃម៉ាក OPPO ចំនួន០១គ្រឿង និងប្រាក់ចំនួនជាង៧០០.០០០(ចិតសិបម៉ឺន)រៀល ប្រាកដមែន។ ការប្រើកាំបិតផ្គាក់ស្ទាក់គម្រាមយកទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ដែលប្រព្រឹត្តដោយជនជាប់ចោទរូបនេះ ត្រូវបានច្បាប់កំណត់ជាអំពើលួចមានស្ថានទម្ងន់ទោស ដែលមានបញ្ញត្តិតាមមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។ ដូច្នេះ តំណាងអយ្យការនៅតែរក្សាការប្ដឹងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទ ដូចក្នុងដីកាសន្និដ្ឋានស្ថាពរទាំងស្រុងដដែល។ សេចក្ដីសន្និដ្ឋានប្ដឹងសុំនេះ មានលក្ខណៈ ត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់អាចឱ្យតុលាការទទួលមកពិចារណា និងសម្រេចសេចក្ដីបាន។

១២-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឈឹម បានធ្វើសេចក្ដីសន្និដ្ឋានការពារថា៖ ក្រោយពីបានស្ដាប់ការសាកសួរដេញដោល និងស្ដាប់អំណានចម្លើយជនដែលពាក់ព័ន្ធនាពេលសវនាការរួចមកឃើញថា៖ កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] ឈឹម បានសារភាពថា៖ ថ្ងៃកើតហេតុរូបគេពិតជាបានប្រើកាំបិតផ្គាក់ ពួនស្ទាក់ចាំគម្រាមយកទ្រព្យសម្បត្តិពីប្រជាពលរដ្ឋ ហើយថ្ងៃនោះគាត់ពិតជាបានគម្រាមយកកាបូបស្ពាយដែលមានទូរស័ព្ទដៃ ចំនួន០១គ្រឿង និងប្រាក់មួយចំនួន ពីជនរងគ្រោះឈ្មោះ [redacted] សាវី បានសម្រេចប្រាកដមែន ប៉ុន្តែក្រោយពេលឃាត់ខ្លួន គាត់បាននាំសមត្ថកិច្ចទៅយកទូរស័ព្ទរបស់ជនរងគ្រោះប្រគល់ជូនជនរងគ្រោះវិញហើយ។ ដូច្នេះក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្លួនសូមឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងផ្ដន្ទាទោសគាត់ក្នុងកម្រិតអប្បបរមាដោយអនុគ្រោះផង ពីព្រោះគាត់ពុំធ្លាប់ត្រូវបានតុលាការផ្ដន្ទាទោសពីមុនមកទេ ហើយអំពើរបស់គាត់ក៏ពុំបណ្ដាលឱ្យមានរបួសដល់ជនរងគ្រោះដែរ។ គាត់ធ្វើសកម្មភាពនេះឡើង គ្រាន់តែដើម្បីបានប្រាក់បន្តិចបន្តួចមក ចាយវាយប៉ុណ្ណោះ ពីព្រោះគាត់ជាជនមានពិការភាព ក្រីក្រ ពុំមានមុខរបរសម្រាប់ចិញ្ចឹមជីវិត និងមានវិបត្តិផ្លូវចិត្តដោយសារការលែងលះពីប្រពន្ធ។ គប្បីតុលាការទទួលមកពិនិត្យ ពិចារណា និងសម្រេចសេចក្ដីតាមច្បាប់។

១៣-ជនជាប់ចោទឈ្មោះ [redacted] ឈឹម សំណូមពរថា: ខ្លួនសូមឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួន ដើម្បីឆាប់បានវិលត្រលប់ទៅរស់នៅក្នុងសង្គមជាតិវិញផង ខ្លួនទទួលស្គាល់កំហុសហើយៗ ខ្លួនសូមសន្យាពេលបានចេញពីពន្ធនាគារវិញ ខ្លួនប្រព្រឹត្តអំពើល្មើសនឹងច្បាប់ទៀតហើយ។ គប្បីតុលាការពិនិត្យ ពិចារណា និងសម្រេចសេចក្ដីតាមច្បាប់។

១៤-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] ឈឹម (អត្តសញ្ញាណខាងលើ) ពីបទលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (កាន់កាំបិតផ្គាក់) ប្រព្រឹត្តនៅចំណុចផ្លូវកោងលើទំនប់អូរចក ខាងកើតស្ពានតាប៊ូ ក្នុងភូមិតាអោគ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ គប្បីតុលាការពិចារណា និងផ្ដន្ទាទោសតាមច្បាប់។

## <u>ហេតុដូច្នេះសម្រេច</u>

១-ផ្ដន្ទាទោសឈ្មោះ [redacted] ឈឹម ភេទប្រុស កើតឆ្នាំ២០០១ អាយុ២២ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០៣(បី)ឆ្នាំគត់ ពីបទ៖លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (កាន់កាំបិតផ្គាក់) ប្រព្រឹត្តនៅចំណុចផ្លូវកោងលើទំនប់អូរចក ខាងកើតស្ពានតាប៊ូ ក្នុងភូមិតាអោគ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣។ បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និងការផ្ដន្ទាទោសមានចែងឱ្យផ្ដន្ទាទោសតាមបទប្បញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

២-ប្រគល់វត្ថុតាងចាប់យកមាន៖ ទូរស័ព្ទដៃម៉ាកអូប៉ូ (OPPO) ពណ៌ខៀវ ចំនួន០១គ្រឿង និងអាវដៃវែងពណ៌ខ្មៅចំនួន០១ ទៅឱ្យម្ចាស់ដើមវិញ តាមបទប្បញ្ញត្តិមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។



Scanned with CamScanner

៣-រឹបអូសវត្ថុតាងចាប់យកមាន៖ កាំបិតផ្គាក់ ចំនួន០១ដើម តាមបទប្បញ្ញត្តិមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឈឹម។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមក្រុមប្រឹក្សា | ចៅក្រមក្រុមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

[redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ០៨រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៦

កំពង់ធំ, ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]